ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៤៧ ព.ណ.ឧ.ជ.ព-ប្រក

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣/ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់ឲ្យពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះ - ការអនុវត្តន៍នូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់។


ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

**ប្រការ ២.-**

ពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ត្រូវជាអ្នកចុះហត្ថលេខាលើពាក្យស្នើសុំចុះក្នុងបញ្ជីពាណិជ្ជកម្មនូវការកែប្រែក្រោយចុះបញ្ជី និងផ្តល់ឯកសារគម្រូវសម្រាប់តម្កល់ទៅឲ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣.-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មផងដែរ ប្រសិនបើសហគ្រាស ក្រុមហ៊ុន មានការកែប្រែក្នុងដំណើរការអាជីវកម្មរបស់ខ្លួនដូចខាងក្រោម៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសារជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ ។
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត
- ការកែប្រែថិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនកូរ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឲ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់ ។

**ប្រការ ៤.-**

ចំពោះការផ្ទេរ ឬលក់ភាគហ៊ុនដូចមានចែងក្នុងប្រការ ៣ ខាងលើ ដើម្បីធានាអះអាង និងទទួលខុសត្រូវលើការផ្ទេរ ឬលក់ភាគហ៊ុនថាពិតជាត្រឹមត្រូវ រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុនត្រូវមានការបញ្ជាក់ដូចខាងក្រោម៖

- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីមេធាវី ឬសារការី នៃព្រះរាជាណាចក្រកម្ពុជា
- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្រៅព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីសារការី ឬអាជ្ញាធរ ដែលមានសមត្ថកិច្ច នៃប្រទេសដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនកំពុងរស់នៅ
- ក្នុងករណី ម្ចាស់ហ៊ុនដែលជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនរបស់ខ្លួនមិនត្រូវការការបញ្ជាក់ពីមេធាវី ឬសារការី នោះសាម៉ីខ្លួនអាចមកចុះហត្ថលេខា និងផ្តិតមេដៃដោយផ្ទាល់នៅចំពោះមុខមន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ ៥.-**

ឯកសារតម្រូវ ដែលត្រូវផ្តល់ជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

- កំណត់ហេតុ និងសេចក្តីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន (ច្បាប់ដើម) ចំនួន ០៣ ច្បាប់
- ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្តូរ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
  (វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណី ក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន)
- ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងរូបថតទំហំ ៤ x ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ ( ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី )
- ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង - ស្ថាប័នពាក់ព័ន្ធ " បើសិនជាមាន " ចំនួន ០៣ ច្បាប់

**ប្រការ ៦.-**

ប្រកាសលេខ ០៩៩MOC/SM2008 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីបែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ុន ចាន់ថុល

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ក្រសួង-ស្ថាប័ន
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ